

# The Architect: Marina Tabassum
# ស្ថាបត្យករ : ម៉ារីណា តាបាស៊ុម

HerStory Foundation
Kazi Istela Imam

Let's Read
The Asia Foundation



ម៉ារីណា តាបាស៊ុម ជាក្មេងស្រីដ៏ពូកែម្នាក់ ដែលបានធំដឹងក្តីឡើងក្នុងប្រទេសបង់ក្លាដែស។ ក្រោយពីសង្គ្រាមត្រូវបានបញ្ចប់ ប្រទេសនេះត្រូវការសាងសង់អគារជាច្រើនឡើងវិញ។ អគារដ៏អស្ចារ្យជាច្រើននៅទីក្រុង ជាពិសេសអគាររដ្ឋសភាជាតិ បានធ្វើឱ្យម៉ារីណាចាប់អារម្មណ៍ និងបានជំរុញទឹកចិត្តនាងឱ្យមានក្តីស្រមៃចង់ក្លាយជាស្ថាបត្យករម្នាក់ ដែលជាអ្នករចនាម៉ូតអគារនានា។



ម៉ារីណា បានខិតខំប្រឹងប្រែងរៀនសូត្រយ៉ាងខ្លាំង ហើយតែង
គិតស្រមើស្រមៃពីប្លង់សាងសង់អគារដែលមានភាពអស្ចារ្យ។
នៅពេលដែលសិស្សដទៃទៀតមានគម្រោងត្រឹមតែសាងសង់
អគារដោយប្រើឥដ្ឋ ស៊ីម៉ងត៍ និងឈើ ម៉ារីណាបែរជាគិតទៅដល់
ការសាងសង់អគារដោយប្រើប្រាស់ធាតុផ្សំធម្មជាតិដូចជា ពន្លឺ
និងខ្យល់ទៅវិញ។ ការរចនាម៉ូតសំណង់អគាររបស់នាងមាន
ភាពធំទូលាយ និងមានខ្យល់អាកាសចេញចូល មានបន្ទប់តូច
ធំប្លែកៗ និងផ្លូវដើរកាត់ទៅមកដ៏គួរឱ្យចាប់អារម្មណ៍។



ម៉ារីណា រស់នៅទីក្រុងដាកា ដែលជារដ្ឋធានីរបស់ប្រទេសបង់ក្លាដែស។ ទីក្រុងដាកាមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស ដោយមានការសាងសង់អគារថ្មីៗជាច្រើនជារៀងរាល់ថ្ងៃ។ គេបានផ្តល់ការងារសាងសង់អគារផ្ទះល្វែងជាច្រើនដល់ម៉ារីណា ប៉ុន្តែនាងមិនទទួលធ្វើការងារសំណង់អគារប្រភេទនោះឡើយ។ ម៉ារីណា មិនចង់ខ្ជះខ្ជាយពេលវេលាទៅលើគម្រោងការងារដែលនាងពុំមានការជឿជាក់ឡើយ។ អ្វីដែលនាងចង់ធ្វើបំផុតនោះគឺសាងសង់អគារដែលបង្កប់ដោយអត្ថន័យនិងអាចប្រាប់ពីរឿងរ៉ាវផ្សេងៗបាន។



ម៉ារីណា បានបើកស្ទូឌីយ៉ូស្ថាបត្យកម្មមួយ ហើយបានរចនាប្លង់ដ៏អស្ចារ្យជាច្រើនដូចជា បន្ទប់ដែលមានសសរទឹក ជញ្ជាំងដែលមានប្រហោង និងពិដានដែលមានទឹកបាញ់ចេញមក។ ក្រោយមក ការរចនារបស់នាងបានក្លាយជាសំណង់ដ៏អស្ចារ្យ និងស្រស់ស្អាត។ ជាមួយគ្នានេះដែរ នាងក៏បានរួមសហការរចនាសារមន្ទីរឯករាជ្យនៅក្នុងទីក្រុងដាកា ដែលមានវិចិត្រសាលនៅក្រោមដី និងទឹកផុសត្រឡប់ចុះក្រោម។



ស្ថានដែមួយដ៏សំខាន់ជាងគេរបស់ម៉ារីណា គឺវិហារអ៊ីស្លាមឈ្មោះ ប៉ៃតធីរ៉ូស ដែលបានធ្វើឱ្យនាងឈ្នះនូវពានរង្វាន់អន្តរជាតិ។ វិហារនោះជាកន្លែងដ៏សាមញ្ញមួយដែលក្មេងប្រុស ក្មេងស្រី អាចមកបន់ស្រន់ និងចំណាយពេលស្រមើស្រមៃ ឬគិតពី អ្វីផ្សេងៗទៀត។ វិហារនេះសង់ឡើងដោយឥដ្ឋពណ៌ក្រហម សុទ្ធសាធ ហើយនៅតាមជញ្ជាំងនិងដំបូលព្រះវិហារមាន ប្រហោងជាច្រើនសម្រាប់ឱ្យខ្យល់និងពន្លឺចេញចូល។ ជាទូទៅ ម៉ារីណា តែងតែរចនាម៉ូតអគារនីមួយៗឡើង គឺសម្រាប់ពេល អនាគតខាងមុខ ដែលមនុស្សគ្រប់គ្នាមានសិទ្ធិសេរីភាពក្នុងការ ធ្វើជាខ្លួនឯង ហើយក្មេងប្រុសនិងក្មេងស្រីមានសិទ្ធិដូចគ្នា។

រឿងសម្រាប់ជំរុញទឹកចិត្តមួយនេះ គឺជាផ្នែកមួយនៃក្រុមសៀវភៅរឿងរបស់ HerStories ដែលត្រូវបានបង្កើតឡើងដោយមូលនិធិ Herstory Foundation ។ រឿងនេះត្រូវបានបោះពុម្ពជាសៀវភៅរឿងដាច់ចេញពីគ្នា តាមរយៈការសហការជាមួយគម្រោងផ្តួចផ្តើមLet’s Read របស់អង្គការមូលនិធិអាស៊ី។ សម្រាប់ព័ត៌មានបន្ថែមពី HerStory សូមចូលទៅកាន់គេហទំព័រ www.herstorybd.org

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*স্থপতি - মেরিনা তাবাসসুম (The Architect: Marina Tabassum)*, Author: HerStory Foundation. Illustrator: Kazi Istela Imam. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC-BY-NC-4.0.

This work is a modified version of the original story. © The Asia Foundation, 2021. Some rights reserved. Released under CC-BY-NC-4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/
Contributing translators: